# ឯកសារទស្សនទាន
# វេទិកាសិក្សាលើកទី ២
# ស្តីពី
# ការឆ្លុះបញ្ចាំងអំពីការប្រតិបត្តិរបស់អង្គការសហគមន៍មូលដ្ឋាន
# ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ និងនិរន្តរភាព

**ថ្ងៃទី ១២-១៣ ខែធ្នូ ឆ្នាំ២០១៧ នៅសណ្ឋាគារកែបឃេ ខេត្តកែប**

## ១. សនិទាន

តាមរបាយការណ៍សិក្សាស្រាវជ្រាវដោយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ក្នុងឆ្នាំ២០១២ បង្ហាញថា មានអង្គការសហគមន៍មូលដ្ឋានប្រមាណជាង ២៥០០០ (ពីរម៉ឺនប្រាំពាន់) ដែលមានវត្តមាននៅក្នុងប្រទេសកម្ពុជា ហើយពួកគាត់ដើរតួនាទីដ៏សំខាន់ក្នុងការអភិវឌ្ឍខាងផ្នែកសេដ្ឋកិច្ចសង្គម និងលើសពីនេះ។ ទោះបីជាយ៉ាងណា ការប្រតិបត្តិរបស់អង្គការសហគមន៍មូលដ្ឋាននៅប្រទេសកម្ពុជានៅតែត្រូវការការលើកកម្ពស់ និងគាំទ្រពីភាគីពាក់ព័ន្ធដទៃទៀត រួមទាំងដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងរដ្ឋាភិបាល។ ដើម្បីជាការចូលរួមក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ និងនិរន្តរភាពរបស់អង្គការសហគមន៍មូលដ្ឋាន គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) ជាមួយនឹងការគាំទ្រពីដៃគូអភិវឌ្ឍ និងក្រុមការងារបច្ចេកទេស គោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាននៅប្រទេសកម្ពុជាត្រូវបានបង្កើតឡើង។ គោលការណ៍នេះកើតចេញពីបទពិសោធន៍នៃការអនុវត្តរបស់កម្មវិធីអភិបាលកិច្ចល្អ និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ ការប្រជុំជាមួយសមាជិកក្រុមការងារបច្ចេកទេសជាច្រើនលើក ច្រើនសារ និងសិក្ខាសាលាពិគ្រោះយោបល់ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាមួយនឹងអង្គការសហគមន៍មូលដ្ឋាន និងភាគីពាក់ព័ន្ធដទៃទៀត។ គោលការណ៍ណែនាំនេះក៏ត្រូវបានធ្វើការសាកល្បងយកទៅបង្រៀនដល់អង្គការសហគមន៍មូលដ្ឋាន ដើម្បីធ្វើអោយប្រាកដថា គោលការណ៍ណែនាំនេះអាចអនុវត្តបាន និងជាមគ្គុទ្ទេសក៍ជំនួយស្មារតីដល់ពួកគាត់ពិតប្រាកដមែន។ ហើយជាលទ្ធផល គោលការណ៍ណែនាំនេះត្រូវបានចាត់ទុកថា ជាមគ្គុទេសក៍ដ៏ល្អ សម្រាប់ជួយដល់អង្គការសហគមន៍មូលដ្ឋាន ក្នុងការអនុវត្តអោយកាន់តែប្រសើរឡើង និងលើកកម្ពស់អភិបាលកិច្ច និងនិរន្តរភាព ប៉ុន្តែទោះជាយ៉ាងណាអង្គការសហគមន៍មូលដ្ឋាននៅតែត្រូវការការខិតខំប្រឹងប្រែងរួមគ្នា ទាំងបច្ចេកទេស ហិរញ្ញវត្ថុ និងការគាំទ្រពីសំណាក់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងរដ្ឋាភិបាល។ ក្នុងកិច្ចអន្តរាគមន៍នេះ កិច្ចប្រជុំនៃភាពជាដៃគូ ដើម្បីលើកកម្ពស់ និងបណ្តុះវប្បធម៌នៃការប្រតិបត្តិល្អ និងនិរន្តរភាពរបស់អង្គការសហគមន៍មូលដ្ឋាន ត្រូវបានរៀបចំឡើងដើម្បីពិភាក្សាស្វែងរកយន្តការនៃភាពជាដៃគូ ប្រកបដោយបរិយាបន្ន ក្នុងការគាំទ្រអង្គការសហគមន៍មូលដ្ឋាន សម្រាប់ការប្រតិបត្តិល្អ និងនិរន្តរភាព។



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,Cambodia

ដើម្បីយកលទ្ធផលពីកិច្ចប្រជុំនៃភាពជាដៃគូនេះ ធ្វើការពិភាក្សាបន្តជាមួយបណ្តាអង្គការដែលចូលរួមសហការក្នុងការរៀបចំវេទិកាសិក្សានេះ និងដើម្បីជាការធ្វើបច្ចុប្បន្នភាព និងឆ្លុះបញ្ចាំង ថាតើសិក្ខាកាមមកពីបណ្តាអង្គការសហគមន៍មូលដ្ឋាន ដែលបានចូលរួមវគ្គបណ្តុះបណ្តាលកាលពីពេលមុន បានអនុវត្ត និងបានធ្វើការផ្លាស់ប្តូរនៅក្នុងអង្គការសហគមន៍មូលដ្ឋានរបស់ពួកគាត់បានដល់កម្រិតណា ហើយថាតើអង្គការសហគមន៍មូលដ្ឋានដែលមិនដែលចូលរួមវគ្គបណ្តុះបណ្តាលគាត់មានការប្រតិបត្តិល្អបានកម្រិតណា និងដើម្បីផ្សព្វផ្សាយសៀវភៅគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាននេះ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា មជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារ និងស្រ្តីនៅកម្ពុជា សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល ខេមរអភិវឌ្ឍន៍សហគមន៍ មជ្ឈមណ្ឌលម្លប់ព្រហ្មវិហារធម៌ និងអង្គការសាមគ្គី បានសហការគ្នារៀបចំវេទិកាសិក្សារៀនសូត្រមួយ ដែលៈ

## ២. វេទិកានេះមានគោលដៅចំបងធំៗគឺៈ

១. ដើម្បីធ្វើការឆ្លុះបញ្ចាំង ថាតើអង្គការសហគមន៍មូលដ្ឋានធ្វើការប្រតិបត្តិល្អតាមគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន និងអភិវឌ្ឍសហគមន៍របស់គាត់បានដល់កម្រិតណា

២. ដើម្បីផ្តល់ឱកាសដល់អង្គការសហគមន៍មូលដ្ឋានក្នុងការពិភាក្សាស្វែងរកការវិធីសាស្ត្រល្អមួយដើម្បីនិរន្តរភាពសម្រាប់សហគមន៍ពួកគាត់

៣. ដើម្បីប្រើប្រាស់នូវយោបល់ត្រលប់ពីអ្នកចូលរួម ដែលអាចធ្វើអោយប្រសើរថែមទៀតនូវការប្រតិបត្តិរបស់អង្គការសហគមន៍មូលដ្ឋាន

៤. ដើម្បីបន្តការផ្សព្វផ្សាយសៀវភៅគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាននៅប្រទេសកម្ពុជា

## ៣. កាលបរិច្ឆេទ និង ទីកន្លែងនៃវេទិកាសិក្សា

**កាលបរិច្ឆេទៈ** ថ្ងៃទី១២-១៣ ខែធ្នូ ឆ្នាំ២០១៧ ម៉ោង ៨ៈ០០ព្រឹក ដល់ ១៧ៈ០០ ល្ងាច

**ទីកន្លែងៈ** សណ្ឋាគារកែបបេ ខេត្តកែប

## ៣. លទ្ធផលរំពឹងទុក

១. អ្នកចូលរួមនឹងពិភាក្សា ត្រួតពិនិត្យ និងចែករំលែកភាពជោគជ័យ និងការប្រឈមកំឡុង ពេលពួកគាត់អនុវត្តនូវខ្លឹមសារសំខាន់ៗក្នុងសៀវភៅគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន

២. អ្នកចូលរួមនឹងស្វែងយល់កាន់តែប្រសើរថែមទៀតពីខ្លឹមសារសំខាន់ៗរបស់គោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន ដើម្បីយកទៅអនុវត្តនៅក្នុងអង្គការសហគមន៍មូលដ្ឋានរបស់ពួកគាត់។



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,Cambodia

Accountability គណនេយ្យភាព
GPP 25/08/2015 24/08/2018
Symbol of Trust

៣. អ្នកចូលរួមនឹងបានសិក្សាពីគ្នាទៅវិញទៅមកអំពីទីផ្សារអាជីវកម្ម និងធនធានដែលមាននៅតាមសហគមន៍នីមួយៗ

៤. អង្គការសហគមន៍មូលដ្ឋាននឹងទទួលបានសៀវភៅគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន ដើម្បីប្រើជាប្រយោជន៍របស់អង្គការខ្លួនផង និងដើម្បីចែករំលែកជាចំណេះដឹងដល់អង្គការសហគមន៍មូលដ្ឋានផ្សេងៗទៀតផង

## ៨. អ្នកចូលរួម

វេទិកាសិក្សានេះនឹងមានអ្នកចូលរួមចំនួនប្រមាណពី ៤០ ទៅ ៥០ នាក់ មកពីអង្គការសហគមន៍មូលដ្ឋាន នៅតាមបណ្តាខេត្តនៃតំបន់ឆ្នេរ រួមមានខេត្តកំពត កែប កំពង់សោម និងកោះកុង។

## ៨. របៀបវារៈ

| *ម៉ោង* | *ការពិភាក្សា* | *អ្នកសម្របសម្រួល* |
|---|---|---|
| **ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧** | | |
| ០៨៖០០ ដល់ ០៨៖៣០ | ចុះឈ្មោះអ្នកចូលរួម | **លោកស្រី អ៊ុង ប៊ុនសូដានី**<br>មន្ត្រីគ្រប់គ្រងផ្នែកជំនួយ |
| ០៨៖៣០ ដល់ ០៨៖៤៥ | ការណែនាំអំពីគោលបំណងនៃវេទិកាសិក្សារបស់អង្គការសហគមន៍មូលដ្ឋាន | **លោកស្រី កៅ សុខដែត**<br>អ្នកឯកទេសផ្នែកអភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ |
| ០៨៖៤៥ ដល់ ០៩៖០០ | សន្ទរកថាស្វាគមន៍ ដោយអ្នកតំណាងមកពីអង្គការដែលសហការក្នុងការរៀបចំវេទិកាសិក្សានេះ | អ្នកតំណាងមកពីអង្គការដែលសហការក្នុងរៀបចំវេទិកាសិក្សានេះ |
| ០៩៖០០ ដល់ ០៩៖១៥ | សន្ទរកថាស្វាគមន៍ និងបើកកម្មវិធី ដោយអង្គការ គ.ស.ក | តំណាងមកពីអង្គការ គ.ស.ក |
| ០៩៖១៥ ដល់ ០៩៖៤០ | បទបង្ហាញអំពី **«គោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន»** | **កញ្ញា កៅ ពៅលក្ខិណា**<br>អ្នកឯកទេសផ្នែកអង្គការសហគមន៍មូលដ្ឋាន |
| ០៩៖៤០ ដល់ ១០៖០០ | សម្រាក និងពិសារអាហារសម្រន់ | ទាំងអស់គ្នា |
| ១០៖០០ ដល់ ១២៖០០ | ការពិភាក្សាជាក្រុមតូចៗ ក្នុងការបង្កើតបញ្ជីសំណួរសម្រាប់ឆ្លុះបញ្ចាំងខ្លួនឯងស្តីពីការប្រតិបត្តិល្អ ធៀបនឹងគោលការណ៍ណែនាំ ស្តីពីការប្រតិបត្តិល្អនៃអង្គការសហគមន៍មូលដ្ឋាន | **កញ្ញា កៅ ពៅលក្ខិណា**<br>អ្នកឯកទេសផ្នែកអង្គការសហគមន៍មូលដ្ឋាន |
| ១២៖០០ ដល់ ១៣៖៣០ | អាហារថ្ងៃត្រង់ | ទាំងអស់គ្នា |
| ០១៖៣០ ដល់ ០៣៖៣០ | ការធ្វើបទបង្ហាញពីក្រុមតូចៗទៅវេទិកាសិក្សាទាំងមូល | តំណាងពីក្រុមពិភាក្សាតូចៗ |



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,Cambodia

| | | |
|---|---|---|
| ០៣៖៣០ ដល់ ០៣៖៤៥ | សម្រាក និងពិសាអាហារសម្រន់ | ទាំងអស់គ្នា |
| ០៣៖៤៥ ដល់ ០៥៖០០ | ការពិភាក្សាជាក្រុមតូចៗ ត្រួតពិនិត្យឡើងវិញ និងឆ្លុះបញ្ចាំងខ្លួនឯងស្តីពីការប្រតិបត្តិល្អ ធៀបនឹងគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អនៃអង្គការសហគមន៍មូលដ្ឋាន ដោយប្រើប្រាស់បញ្ជីសំណួរ | **លោកស្រី កៅ សុខដែត**<br>អ្នកឯកទេសផ្នែកអភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ<br>អ្នកតំណាងមកពីអង្គការដែលសហការក្នុងរៀបចំវេទិកាសិក្សានេះ |
| **ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧** | | |
| ០៨៖០០ ដល់ ០៨៖១៥ | រំលឹកមេរៀនថ្ងៃទីមួយ | **កញ្ញា កៅ ពៅលក្ខិណា**<br>អ្នកឯកទេសផ្នែកអង្គការសហគមន៍មូលដ្ឋាន |
| ០៨៖១៥ ដល់ ១០៖០០ | ការធ្វើបទបង្ហាញពីក្រុមតូចៗទៅវេទិកាសិក្សាទាំងមូល | តំណាងពីក្រុមពិភាក្សាតូចៗ |
| ១០៖០០ ដល់ ១០៖១៥ | សម្រាក និងពិសាអាហារសម្រន់ | ទាំងអស់គ្នា |
| ១០៖១៥ ដល់ ១២៖០០ | ការពិភាក្សាជាក្រុមតូចៗ<br>កិច្ចពិភាក្សាទៅលើ ទីផ្សារ ការធ្វើផែនទីធនធាន និងការបង្កើតសមាគមសម្រាប់អង្គការសហគមន៍មូលដ្ឋាន | **កញ្ញា កៅ ពៅលក្ខិណា**<br>អ្នកឯកទេសផ្នែកអង្គការសហគមន៍មូលដ្ឋាន<br>អ្នកតំណាងមកពីអង្គការដែលសហការក្នុងរៀបចំវេទិកាសិក្សានេះ |
| ១២៖០០ ដល់ ១៣៖៣០ | អាហារថ្ងៃត្រង់ | ទាំងអស់គ្នា |
| ១៣៖៣០ ដល់ ០២៖៤៥ | ការពិភាក្សាជាក្រុមតូចៗ (ពិភាក្សាបន្ត)<br>កិច្ចពិភាក្សាទៅលើ ទីផ្សារ ការធ្វើផែនទីធនធាន និងការបង្កើតសមាគម សម្រាប់អង្គការសហគមន៍មូលដ្ឋាន | **កញ្ញា កៅ ពៅលក្ខិណា**<br>អ្នកឯកទេសផ្នែកអង្គការសហគមន៍មូលដ្ឋាន<br>អ្នកតំណាងមកពីអង្គការដែលសហការក្នុងរៀបចំវេទិកាសិក្សានេះ |
| ០២៖៤៥ ដល់ ០៣៖០០ | សម្រាក និង ពិសាអាហារសម្រន់ | ទាំងអស់គ្នា |
| ០៣៖០០ ដល់ ០៤៖៤៥ | ការធ្វើបទបង្ហាញពីក្រុមតូចៗទៅវេទិកាសិក្សាទាំងមូល | តំណាងពីក្រុមពិភាក្សាតូចៗ |
| ០៤៖៤៥ ដល់ ០៥៖០០ | សុន្ទរកថាបិទ | តំណាងមកពីអង្គការ គ.ស.ក |


www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,Cambodia
Accountability គណនេយ្យភាព
អភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ
GPP
25/08/2015 24/08/2018
Symbol of Trust និមិត្តសញ្ញានៃភាពទុកចិត្ត